**សុន្ទរកថារបស់ លោក ម៉ាត់ស៊ូម៉ូតុ អ៊ីហ្សូមី**

លេខាទីពីរ ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីសម្ពោធអគារសិក្សាថ្មីមួយខ្នងនៅសាលាបឋមសិក្សាខ្លែងពណ៌

ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

**ថ្ងៃទី ១៩ ខែកក្កដា ២០១៦**

- សូមគោរព **លោក Patrick Seger** នាយកប្រចាំប្រទេសនៃអង្គការSamaritan's Purse International Relief
- សូមគោរព **ឯកឧត្តម អ៊ុំ រាត្រី** អភិបាលរងខេត្តបន្ទាយមានជ័យ
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានសេចក្ដីសោមនស្សរីករាយ ដែលបានមកចូលរួមក្នុងពិធីសម្ពោធអគារសិក្សាមួយខ្នងនៅសាលាបឋមសិក្សាខ្លែងពណ៌ ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុំ រាត្រី** អភិបាលរងខេត្តបន្ទាយមានជ័យ។ ជាបឋម ខ្ញុំសូមសម្ដែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងអប់រំ យុវជន និងកីឡា និងជាពិសេសអង្គការ Samaritan's Purse International Relief ដែលបានផ្តួចផ្តើមគំនិត និងអនុវត្តគម្រោងនេះយ៉ាងសកម្ម។

ខ្ញុំសូមសម្ដែងនូវការកោតសរសើរ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការកែលម្អវិស័យអប់រំ ចាប់តាំងពីសង្គ្រាមផ្ទៃក្នុងត្រូវបានបញ្ចប់។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំថា ជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនោះ រដ្ឋាភិបាលជប៉ុនបាននឹងកំពុងបន្តគាំទ្រជំនួយឧបត្ថម្ភរបស់ខ្លួនដល់កម្ពុជាតាមរយៈគ្រោងការណ៍ជាច្រើនបែបដែលក្នុងនោះក៏មាន គ្រោងការណ៍ជំនួយឥតសំណងជប៉ុនសម្រាប់គម្រោងទ្រង់ទ្រាយតូច ហៅកាត់ថាគម្រោងគូសាណូណិ។ គម្រោងនេះ គឺជាគម្រោងទី៤ ដែលត្រូវបានសាងសង់ដោយគម្រោងគូសាណូណិនៅក្នុងខេត្តបន្ទាយមានជ័យនេះ។

ខ្ញុំបានទទួលដំណឹងថា សិស្សានុសិស្សប្រមាណជា ៧២នាក់នៅសាលាបឋមសិក្សាខ្លែងពណ៌នេះ ត្រូវសិក្សានៅក្នុងបរិស្ថានសិក្សាដែលមិនមានផាសុខភាព និងសុវត្ថិភាព។ តែឥឡូវនេះ បានជំនួសមកវិញដោយអគារសិក្សាថ្មីមួយខ្នងមាន៤បន្ទប់ ដែលទើបតែត្រូវបានសាងសង់រួច សម្រាប់ក្មួយៗសិស្សានុសិស្សទាំងអស់នៅសាលាបឋមសិក្សាខ្លែងពណ៌នេះ។

ខ្ញុំពិតជាមានសេចក្ដីរីករាយក្រៃលែងដែលបានឃើញ សិស្សានុសិស្សនៃសាលាបឋមសិក្សាខ្លែងពណ៌នេះអាចសិក្សានៅក្នុងអគារសិក្សាដែលប្រកបដោយសុវត្ថិភាពនិងផាសុខភាព។ ខ្ញុំសង្ឃឹមថា អគារសិក្សាថ្មីនេះ នឹងត្រូវបានថែទាំយ៉ាងត្រឹមត្រូវអោយបាននៅគង់វង្សល្អ ដើម្បីទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសម្ដែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើអោយគម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្ដាប់!**

**សុន្ទរកថារបស់ លោក ម៉ាត់ស៊ូម៉ូតុ អ៊ីហ្សូមី**

លេខាទីពីរ ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ
ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅសាលាបឋមសិក្សាតាដុល ក្នុងស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ
ថ្ងៃទី ២០ ខែកក្កដា ២០១៦

- សូមគោរព **លោក** Patrick Seger នាយកអង្គការSamaritan's Purse International Relief
- សូមគោរព **ឯកឧត្តម លី សារី** អភិបាលរងខេត្តបន្ទាយមានជ័យ
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានមកចូលរួមក្នុងពិធីសម្ពោធអគារសិក្សាមួយខ្នងនៅសាលាបឋមសិក្សាតាដុល ជាមួយនឹងវត្តមានរបស់ **ឯកឧត្តម លី សារី** អភិបាលរងខេត្តបន្ទាយមានជ័យ។ ជាបឋម ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងអប់រំ យុវជន និងកីឡា និងជាពិសេស អង្គការ Samaritan's Purse International Relief ដែលបានផ្តួចផ្តើមគំនិត និងអនុវត្តគម្រោងនេះយ៉ាងសកម្ម។

ខ្ញុំសូមសម្តែងនូវការកោតសរសើរម្តងទៀត ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការកែលម្អវិស័យអប់រំ ចាប់តាំងពីសង្គ្រាមផ្ទៃក្នុងត្រូវបានបញ្ចប់។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំថា ជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនោះ រដ្ឋាភិបាលជប៉ុនបាននឹងកំពុងបន្តផ្តល់ការគាំទ្រជំនួយឧបត្ថម្ភរបស់ខ្លួនដល់កម្ពុជា តាមរយៈគ្រោងការណ៍ជាច្រើនបែបដែលក្នុងនោះក៏មាន គ្រោងការណ៍ជំនួយឥតសំណងជប៉ុនសម្រាប់គម្រោងទ្រង់ទ្រាយតូច ហៅកាត់ថាគម្រោងគូសាណូណេ។ គម្រោងនេះ គឺជាគម្រោងទី៤ ដែលត្រូវបានសាងសង់ដោយគម្រោងគូសាណូណេនៅក្នុងខេត្តបន្ទាយមានជ័យនេះ។

ខ្ញុំបានទទួលដំណឹងថា សិស្សានុសិស្សប្រមាណជា ១៨៤នាក់នៅសាលាបឋមសិក្សាតាដុល ត្រូវសិក្សានៅក្នុងបរិស្ថានការសិក្សាដែលមិនមានជាសុខភាព និងសុវត្ថិភាព។ ហើយឥឡូវនេះបានជំនួសមកវិញដោយអគារសិក្សាថ្មីមួយខ្នងមាន៤បន្ទប់ ដែលទើបតែត្រូវបានសាងសង់រួច សម្រាប់ក្មួយៗសិស្សានុសិស្សទាំងអស់នៅសាលាបឋមសិក្សាតាដុល។

ខ្ញុំពិតជាមានសេចក្តីរីករាយ ដែលបានឃើញសិស្សានុសិស្សនៃសាលាបឋមសិក្សាតាដុលទាំងអស់ អាចធ្វើការសិក្សានៅក្នុងអគារសិក្សាដែលប្រកបដោយសុវត្ថិភាព និងជាសុខភាព។ ដូច្នេះសូមក្មួយៗរួមគ្នាជួយថែរក្សាអគារសិក្សានេះអោយបាននៅគង់វង្សល្អដើម្បីទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាពរវាងប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើអោយគម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**